## ការស្ទង់មតិស្តីពីសមធម៌សុខភាពសហគមន៍ ឆ្នាំ 2026៖ ចំណុចសំខាន់សម្រាប់ការផ្សព្វផ្សាយ

*ខាងក្រោមនេះគឺជាចំណុចសំខាន់សម្រាប់ការផ្សព្វផ្សាយ ដោយមានព័ត៌មានលម្អិតបន្ថែមនៅ ក្នុងចំណុចរង។ សូមប្រើចំណុចសំខាន់ទាំងនេះក្នុងឯកសារផ្សព្វផ្សាយ បណ្តាញសង្គម កិច្ចប្រជុំ និងការសន្ទនាផ្ទាល់ជាមួយសមាជិកសហគមន៍។ សូមជ្រើសរើស ឬកែសម្រួលចំណុចសំខាន់ឱ្យសមស្រប ដើម្បីឱ្យមានប្រសិទ្ធភាពបំផុតសម្រាប់ការទំនាក់ទំនងជាមួយសហគមន៍របស់អ្នក។*

នៅទូទាំងរដ្ឋម៉ាសាឈូសេត មានការសម្រេចចិត្តជារៀងរាល់ថ្ងៃអំពីតម្រូវការ អាទិភាព ដំណោះស្រាយ និងធនធានរបស់សហគមន៍។ បទពិសោធន៍របស់អ្នកគួរតែជាផ្នែកមួយដែលជួយកំណត់ការសម្រេ ចចិត្តទាំងនោះ។

- អ្នកគឺជាអ្នកជំនាញអំពីអ្វីដែលធ្វើឱ្យសហគមន៍របស់អ្នកមានសុខភាពល្អ។ នៅពេលអ្ន កចូលរួមការស្ទង់មតិ អ្នកកំពុងចែករំលែកតម្លៃ តម្រូវការ និងក្តីសង្ឃឹមរបស់អ្នកសម្រា ប់អនាគត។
- ដោយផ្អែកលើបទពិសោធន៍របស់សមាជិកសហគមន៍ ទិន្នន័យពីការស្ទង់មតិជួយឱ្យ អង្គការមូលដ្ឋានគាំទ្រគោលនយោបាយដែលមានសមធម៌ ដាក់ពាក្យស្នើសុំថវិកាដើម្បីបំពេ ញតម្រូវការក្នុងមូលដ្ឋាន និងកែសម្រួលកម្មវិធីឱ្យសមស្របបំផុតសម្រាប់បម្រើ សហគមន៍របស់ពួកគេ។ នៅកម្រិតរដ្ឋ ទិន្នន័យពីការស្ទង់មតិជួយវាស់វែងតម្រូវការផ្នែ កសុខភាព និងសង្គមដែលមានលក្ខណៈពិសេសរបស់សហគមន៍នីមួយៗ កំណត់ឱកាសក្នុងការដោះស្រាយវិសមភាព និងកំណត់អាទិភាពក្នុងការបែងចែកធនធាន។

ការស្ទង់មតិស្តីពីសមធម៌សុខភាពសហគមន៍ ជួយលើកកម្ពស់ការចូលរួមរបស់ក្រុមប្រជាជនដែលជាញឹ កញាប់មិនសូវត្រូវបានតំណាងនៅក្នុងទិន្នន័យសំខាន់ៗ ដូចជាទិន្នន័យអំពីសុខភាព និងសុខុមាលភាពរបស់ពួកគេ។ តាមរយៈការចូលរួមការស្ទង់មតិ អ្នកកំពុងបន្ថែមបទពិសោធន៍ និងចំណេះដឹងរបស់អ្នក ហើយធានាថាសហគមន៍របស់អ្នកត្រូវបានតំណាង។

បច្ចុប្បន្ន យើងកំពុងប្រឈមមុខនឹងការគំរាមកំហែងប្រភេទថ្មីៗចំពោះសុខភាព និងសុវត្ថិភាព របស់សហគមន៍ ដែលជាប្រវត្តិសាស្ត្រមកតែងតែត្រូវបានបដិសេធឱកាសស្មើគ្នាក្នុងការទទួលបាន សុខភាព។ ឥឡូវនេះ ជាងពេលណាៗទាំងអស់ ទិន្នន័យដែលផ្តោតលើសមធម៌ ដូចជាទិន្នន័យពី CHEI មានសារៈសំខាន់ជាចាំបាច់។

- រដ្ឋម៉ាសាឈូសេតកំពុងខិតខំធានាថា សហគមន៍ដែលពីមុនមកមិនសូវត្រូវបានតំណាង ឬមិនត្រូវបានមើលឃើញនៅក្នុងទិន្នន័យ និងដំណើរការធ្វើសេចក្តីសម្រេចចិត្ត មានឱកាសបញ្ចេញសំឡេងរបស់ពួកគេ ជាពិសេសនៅក្នុងបរិបទបច្ចុប្បន្ន។
- វាមានសារៈសំខាន់ក្នុងការប្រមូលបទពិសោធន៍ និងវាយតម្លៃផលប៉ះពាល់នៃគោលនយោបាយ និងវិធានការបច្ចុប្បន្ន ទៅលើសហគមន៍ដែលប្រឈមនឹងហានិភ័យខ្ពស់បំផុត។

CHEI យល់ដឹងអំពីបរិយាកាសដែលយើងកំពុងរស់នៅ និងធ្វើការ ព្រមទាំងការព្រួយបារម្ភ និងការភ័យខ្លាចដែលមនុស្សកំពុងជួបប្រទះក្នុងជីវិតប្រចាំថ្ងៃ។

- ការចូលរួមក្នុងការស្ទង់មតិស្តីពីសមធម៌សុខភាពសហគមន៍ គឺស្ម័គ្រចិត្តទាំងស្រុង និងរក្សាអនាមិកភាពពេញលេញ។ ការស្ទង់មតិនេះមិនស្នើសុំព័ត៌មានដែលអាចកំណ ត់អត្តសញ្ញាណផ្ទាល់ខ្លួនណាមួយ (ដូចជា ឈ្មោះ លេខទូរស័ព្ទ ឬអាសយដ្ឋានអ៊ីមែល) ឡើយ។ អ្នកអាចរំលងសំណួរណាមួយដែលអ្នកមិនចង់ឆ្លើយបាន។
- ចម្លើយ និងទិន្នន័យទាំងអស់ពីការស្ទង់មតិ ត្រូវបានរក្សាទុកជាអនាមិក ហើយទិន្នន័យដែលត្រូវបានចែករំលែកនឹងត្រូវបានបូកបញ្ចូលជាមួយចម្លើយផ្សេងៗ (ទិន្នន័យសរុប) ដោយមិនអាចកំណត់អត្តសញ្ញាណបុគ្គលបាន។